**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ..០៧...សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យព្រះសពសម្ដេចព្រះឧត្តមមុនីកិត្តិបណ្ឌិត ឃឿង យ៉ាត់ សមាជិកថេរសភាព្រះពុទ្ធសាសនា នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តជ្រោយអំពិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១** ៖ ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យព្រះសពសម្ដេចព្រះឧត្តមមុនីកិត្តិបណ្ឌិត **ឃឿង យ៉ាត់** សមាជិកថេរសភាព្រះពុទ្ធសាសនា នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តជ្រោយអំពិល ដែលមានសមាសភាពដូចខាងក្រោម ៖

១. សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** ព្រះប្រធានកិត្តិយស

២. សម្ដេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** ព្រះប្រធានកិត្តិយស

៣. ឯកឧត្ដមទេសរដ្ឋមន្ត្រី **ហ៊ឹម ឆែម** ប្រធាន

៤. សម្ដេចព្រះពោធិវ័ង្ស **អ៊ំ លីមហេង** ព្រះអនុប្រធាន

www.pheakdeylaw.com

| | | |
|---|---|---|
| ៥. សម្តេចព្រះវន័រ័ត | **ណាយ ច្រឹក** | ព្រះអនុប្រធាន |
| ៦. ព្រះចតុម្មុខមង្គលរង្សី | **ឃឹម សន** | ព្រះអនុប្រធានអចិន្ត្រៃយ៍ |
| ៧. ឯកឧត្តម | **ទន្សី ចិស្សុត** | សមាជិក |
| ៨. ឯកឧត្តម | **ហ៊ុន ស៊ីថា** | សមាជិក |
| ៩. ឯកឧត្តមនាយឧត្តមសេនីយ៍ | **ហ៊ីង ប៊ុនហៀង** | សមាជិក |
| ១០. ឯកឧត្តម | **ឈិន កេតនា** | សមាជិក |
| ១១. ឯកឧត្តមនាយឧត្តមសេនីយ៍ | **សៅ សុខា** | សមាជិក |
| ១២. ឯកឧត្តម | **មួន លឹមហេង** | សមាជិក |
| ១៣. ឯកឧត្តម | **ញ៉ែម ម៉ាលី** | សមាជិក |
| ១៤. ឯកឧត្តម | **ហាក់ ម៉ុនធឿន** | សមាជិក |
| ១៥. ឯកឧត្តម | **សារ៉ាយ ឆុន** | សមាជិក |
| ១៦. ឯកឧត្តម | **ឃួង ស្រេង** | សមាជិក |
| ១៧. ឯកឧត្តមនាយឧត្តមសេនីយ៍ | **ឥត សារ៉ាត់** | សមាជិក |
| ១៨. ឯកឧត្តមនាយឧត្តមសេនីយ៍ | **ជួន សុវណ្ណ** | សមាជិក |
| ១៩. តំណាងអាចារ្យ គណៈកម្មការវត្តជ្រោយអំពិល | | សមាជិក |

**ប្រការ ២ ៖** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ៖

- រួមសហការជាមួយក្រសួង-ស្ថាប័ននានា និងគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំពិធីបុណ្យតាមប្រពៃណីជាតិ ប្រព្រឹត្តទៅឲ្យបានល្អប្រសើរ
- ទទួលបន្ទុករៀបចំក្បួនដង្ហែព្រះសព តុបតែងរថយន្តបុស្បុក និងធ្វើមេរុបូជាព្រះសពសម្តេចព្រះឧត្តមមុនីកិត្តិបណ្ឌិត **ឃឿង យ៉ាត់** ឲ្យបានសមស្របតាមប្រពៃណីព្រះពុទ្ធសាសនា និងស័ក្តិសមទៅនឹងកិត្តិយសរបស់ព្រះសព
- ពិនិត្យ និងលើកសំណើដោះស្រាយរាល់ការលំបាកនានា ទាក់ទិននឹងការរៀបចំបុណ្យព្រះសព
- រៀបចំឲ្យមានកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីបុណ្យព្រះសព និងពេលដង្ហែព្រះសពឲ្យបានល្អប្រសើរ
- ធ្វើកម្មវិធីអញ្ជើញថ្នាក់ដឹកនាំ ចូលរួមដង្ហែ និងបូជាព្រះសព ធ្វើប្លង់ដង្ហែព្រះសព ។ល។
- រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវដែលបានអញ្ជើញចូលរួមក្នុងពិធីបុណ្យព្រះសព និងគោរពព្រះវិញ្ញាណក្ខ័ន្ធ
- រៀបចំវេទិកាសម្រាប់ភ្ញៀវកិត្តិយស ព្រះសង្ឃ និងពុទ្ធបរិស័ទ កៅអី តុ សាជក គេសជ្ជៈ ផ្កាចន្ទន៍ក្រឹស្នា ។ល។

- លើកគម្រោង និងគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ និងសប្បុរសជន ក្នុងការបម្រើឲ្យពិធីបុណ្យប្រព្រឹត្តទៅបានល្អប្រសើរ
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បម្រើឲ្យពិធីបុណ្យ ។

**ប្រការ ៣ ៖** គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីជានាឲ្យការរៀបចំបុណ្យព្រះសព ប្រព្រឹត្តទៅតាមប្រពៃណី បានល្អប្រសើរ ។ គណៈកម្មការនេះ អាចប្រើប្រាស់ត្រាក្រសួងធម្មការ និងសាសនា ដើម្បីដំណើរការសកម្មភាពការងាររបស់ខ្លួន ។

**ប្រការ ៤ ៖** រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ [illegible] ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *សម្តេចព្រះអគ្គមហាសង្ឃរាជ **ទេព វង្ស***
- *គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ក្រសួងការពារជាតិ*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងធម្មការ និងសាសនា*
- *គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ*
- *សាលារាជធានីភ្នំពេញ*
- *រាជកិច្ច*
- *ដូចប្រការ ៤ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com